Buddhist Institute

គយ-សារុន

# កំណាព្យ

# បុប្ផខ្មៅ



ជីវិតនិស្សិត

(សម្រង់អត្ថបទ)

៣១៧.
៣៧

Buddhist Institute

៣១៧.
៣៧

កំណាព្យ

# បុប្ផាខ្មៅ

## ជីវិតនិស្សិត

(សម្រង់អត្ថបទ)

បោះពុម្ពលើកទី ១
ចំនួន ២.៥០០ ក្បាល
ខែវិច្ឆិកា ១៩៧០

គយ.សារុន

រក្សាសិទ្ធិ

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
៥៤៨០/០១

Buddhist Institute



# ជំរាបអ្នកអាន

នេះជាលើកដំបូង ដែលផ្សាយអត្ថបទស្នាដៃ។

តាមពិត ខ្ញុំបានចាប់ផ្ដើមរៀនសរសេរតាំងពីឆ្នាំ ១៩៥៨ គឺតាំងពីខ្ញុំនៅរៀនថ្នាក់ទី ៤ នៃវិទ្យាល័យ ស៊ីសុវត្ថិ (បច្ចុប្បន្នវិទ្យាល័យភ្នំដូនពេញ)

ស្នាដៃកំណាព្យទី ១ របស់ខ្ញុំឈ្មោះ **ជំទិតនិស្សិត** ត្រូវបានជាប់លេខ ៣ ក្នុងការប្រលងប្រជែងអក្សរសាស្ត្រ ១៩៥៩ ខាងក្រសួងអប់រំជាតិ ។ ខ្ញុំមិនបានបោះពុម្ពផ្សាយស្នាដៃនោះទេ ព្រោះយល់ថាគំនិតខ្ញុំនៅខ្ចីណាស់ ហើយខ្ញុំច្រើនសរសេរពីរឿងផ្ទាល់ខ្លួនផង។

ជោគជ័យដ៏តូចមួយនោះ គ្រាន់តែបានបណ្ដុះចិត្តខ្ញុំឱ្យមានសេចក្ដីសង្ឃឹមក្នុងការសរសេរប៉ុណ្ណោះ ។ ខ្ញុំបានចិញ្ចឹមចិត្តនោះជានិច្ចរហូតមកដល់ឆ្នាំ ១៩៦៥ ទើបខ្ញុំចង់សាកល្បងសរសេរម្ដងទៀត។

កំណាព្យឈ្មោះបុប្ផាខ្មៅ ក៏កើតមានរូបរាងឡើងហើយ

Buddhist Institute



បានជាប់លេខ ២ ក្នុងការប្រឡងអក្សរសាស្ត្រឆ្នាំ ១៩៦៧ ។ ប៉ុន្តែទោះបីឱ្យជាប់ដូច្នេះហើយក៏ដោយ មេប្រយោគកែវិញ្ញាសារបស់ខ្ញុំមានលោក **ឈឹម ស៊ុម, ឈុក-ម៉ុខ-ម៉ៅ** ជាដើម ដែលខ្ញុំបានទៅជួបក៏បានសម្តែងនូវការបារម្ភខ្លះដែរ ។

ខ្ញុំត្រូវគិតច្រើនក្នុងរឿងនេះ . . .

ហើយក៏សម្រេចចិត្តមិនផ្សាយស្នាដៃនេះមួយទៀត. គ្រាន់តែបានបង្ហាញមិត្តភក្តិជិតដិតដែលចង់ឃើញប៉ុណ្ណោះ ។

ឥឡូវនេះ ដោយសេរីភាពក្នុងការសរសេរក៏មានហើយ ឯមិត្តភ័ក្តិក៏ចេះតែសួររក ខ្ញុំយល់ថាមិនគួរទុកចោលស្នាដៃនេះតទៀតទេ។ ម្យ៉ាងទៀតខ្ញុំយល់ថា ការដែលក្រសួងអប់រំជាតិក្តី សមាគមអ្នកនិពន្ធខ្មែរក្តី ខំរៀបចំការប្រឡងប្រជែងអក្សរសាស្ត្រ និងការដែលលោកអ្នកសប្បុរសខំផ្តល់អំណោយដល់ជ័យលាភី មិនមែនគ្រាន់តែចង់លើកទឹកចិត្តអ្នកសរសេរប៉ុណ្ណោះទេ គឺច្បាស់ជាមានឧត្តមគតិខ្ពង់ខ្ពស់ចង់ឱ្យអក្សរសាស្ត្រខ្មែរល្អូតលាស់ដើម្បីជាប្រយោជន៍ទូទៅ ។ បច្ចុប្បន្ននេះខ្ញុំយល់ថាជាឳកាសដែលខ្ញុំត្រូវបម្រើឧត្តមគតិនេះហើយ ទោះបីបានច្រើនក្តី តិចក្តី ។

Buddhist Institute



ជាមួយនឹងស្នាដៃទី២ ឈ្មោះ **មុន្នាខ្មៅ** នេះខ្ញុំសូមជូនស្នាដៃទី១ ឈ្មោះ **ជីវិតនិស្សិត** ផងដែរ ប៉ុន្តែគ្រាន់តែធ្វើសម្រង់អត្ថបទខ្លះដែលខ្ញុំនៅស្រឡាញ់ហើយមិនចង់ឱ្យបាត់បង់។

X X X

ក្នុងការផ្ដើមផ្សាយស្នាដៃជាដំបូងនេះ ខ្ញុំសូមផ្ញើជូនតាមរយៈសៀវភៅនេះ នូវអំណរគុណដ៏ស្មោះរបស់ខ្ញុំចំពោះ ÷

- ក្រសួងអប់រំជាតិ ដែលបានបណ្ដុះសេចក្ដីសង្ឃឹមឱ្យខ្ញុំជាដំបូង ក្នុងការសរសេរ ;

- សមាគមអ្នកនិពន្ធខ្មែរ ដែលបានបម្រើវប្បធម៌អក្សរសាស្ត្រខ្មែរពិត ៗ :

- លោកអ្នកសប្បុរស[illegible]អំណោយដល់ជ័យលាភីដើម្បីការលូតលាស់នៃអក្សរសាស្ត្រ[illegible] ;

- អ្នកសរសេរផ្សាយស្នាដៃមុនៗ ខ្ញុំទាំងអស់ ដែលស្នាដៃរបស់លោក បានជាពន្លឺដល់ខ្ញុំ ;

- លោក **ញ៉ូក-សៀង**, **រ៉ាយ-ម៉ុត**, **តេង-ទាន់សាវក់** ដែលនាំឱ្យខ្ញុំស្រឡាញ់កំណាព្យ . ចេះកំណាព្យ.

Buddhist Institute



យល់កំណាព្យ តាមរយៈទស្សនាវដ្ដីមិត្តសាលាបាលី, កម្ពុជសុរិយា, សៀវភៅសកុន្តលា, ចិត្តក្រមុំ, គុកកាមកិលេស ;

- លោក **ឈីមស៊ុម, ឈុត ម៉ឺង ម៉ៅ, ហ្វូ តុង ហ្វូ** ដែលបានពិនិត្យស្នាដៃខ្ញុំ . សរសើរខ្ញុំ, រិះគន់ខ្ញុំនិងឱ្យយោបល់ល្អៗ ដល់ខ្ញុំក្នុងការសរសេរ ។

X X X

ជាបញ្ចប់នេះ ខ្ញុំអរគុណប្អូន **ឃុន ស្រ៊ុន** ដែលបានសរសើរស្នាដៃខ្ញុំតាមសារពត៌មាន និងតាមសៀវភៅគំហើយលេខ ២- លេខ ៣ ហើយថែមទាំងយកចិត្តទុកដាក់ជួយចាត់ចែងបោះពុម្ពសៀវភៅនេះទៀតផង ។

គយ_សារុន

១០-១១-៧០

Buddhist Institute



# ឈ្មោះអត្ថបទ

ទំព័រ

១- បុព្វបទ . . . ៣
២- ឱដើមអម្ពិលទឹក . . . ៥
៣- " បទុមសុរិយា " ផ្សាយរូប . . ៧
៤- ទំព័រសៀវភៅ , ទំព័រជីវិត . . ៩
៥- សូនងងឹត . . . . ១១
៦- សីលធម៌សុំញ៉ែម. . . . ១៣
៧- សុរិយាក្តៅខ្លាំង. . . . ១៥
៨- សំណើចចំអកនៃទឹកប្រាក់ . . ១៦
៩- វិលវិញឬអូន . . . ១៧
១០- ខ្ញុំតាមមិនទាន់ . . . ១៨
១១- អភ័ព្វកម្លោះស្រុកស្រែ . . . ២០
១២- ប្រតិភូក្បត់ពូជ . . . ២១
១៣- ក្រឡាស់ចិត្តទេដឹង . . . ២៣
១៤- ឱ្យខ្ញុំសប្បាយដូចម្តេចកើត? . . ២៥

Buddhist Institute



១៥- នគរច្រើងប្លែក . . .. ២៦
១៦- វិធីក្រមអ៊ូ . . . . ២៨
១៧- តិចឬច្រើន . . . . ៣០
១៨- ព្រះសង្ឃនិមន្តបិណ្ឌបាត្រ . . ៣១
១៩- សម្រាកមួយភ្លែត . . . ៣៣
២០- រកស្ងប់គេថាចាញ់ . . . ៣៦
២១- អាស្ងួរដើមដូង . . . ៣៧
២២- ស្តាយដូងចន្ទ្រា . . . ៣៩
២៣- ជីវិតនិស្សិត . . . . ៤២
២៤- នឹកផ្ទះ . . . . ៤៣
២៥- លាការសិក្សា . . . . ៤៨
២៦- សម្រេចចិត្ត . . . ៥១

Buddhist Institute



# បុព្វបទ

ប្រហែលជាខ្ញុំវង្វេងទេដឹង បានជាឃើញការស៊ីផឹកសប្បាយនៅតាមផ្ទះបារ ខ្ញុំចេះតែគិតទៅដល់ការស្រេកឃ្លានខ្វះខាតនៃអ្នកក្រខ្សត់. ឃើញយុវជនសិស្សសាលាខ្លះ ហ៊ឺហាហក់លោតរាំរែក ខ្ញុំគិតទៅដល់យុវជនខ្លះទៀត ដែលស្លៀកពាក់ខោអាវចាស់ៗ ជួនកាលមានប៉ះដោយកន្លែង ខ្វះប្រដាប់ប្រដារៀនសូត្រ ខ្វះលុយបង់ថ្លៃសាលា ឬលះបង់ការសិក្សាតែម្តង . ឃើញផ្ទះថ្មធំៗ រថយន្តថ្លៃ ៗ ខ្ញុំនឹកឃើញទៅដល់ការខ្វល់ខ្វាយរបស់មនុស្សដើម្បីរកវត្ថុទាំងនោះ ដោយជួនកាលលែងទាំងគិតគូរដល់ការត្រូវ-ខុស .ល្អ-អាក្រក់ទៀតផង ។

ខ្ញុំឃើញអ្វីៗ ទាំងនោះ ដូចដែលអ្នកនិពន្ធនៃ " វិមាននរក " ឃើញសម្លៀកបំពាក់ស្រីបារជាក្រដាសប្រាក់ ២០០.៥០០ ហើយគឺប្រាក់នេះ ដែលអ្នកក្ររកស៊ីបែកញើសហូរញើសច្រើនថ្ងៃខែទំរាំនឹងឈោងចាប់បាន ចំណែកឯអ្នកមានឬអ្នក "រកបានងាយ" គេបែរជាយកទៅពង្រាយចោលទៅវិញ ។

Buddhist Institute



តែប្រសិនបើខ្ញុំមិនវង្វេងទេនោះ នុះតឹមកតែពីខ្ញុំធ្លាប់រស់នៅក្នុងទឹក-ផុក នៃស្រុកស្រែ. ធ្លាប់ចិញ្ចឹមជីវិតដោយសារបាយបាត្រព្រះសង្ឃដើម្បីរៀនសូត្រ. ធ្លាប់ចាកចោលជើងម៉ារៀវទ្យាល័យទាំងទឹកភ្នែក ហើយបើយ៉ាងតិចណាស់ក៏ខ្ញុំមិនចង់ឃើញយុវជនដែលកើតក្នុងត្រកូលក្រខ្សត់ ជួបនឹងឧបសគ្គគ្រប់បែបគ្រប់យ៉ាង មិនអាចនឹងរៀនសូត្រកសាងអនាគតឱ្យសមតាមប្រាជ្ញាស្មារតីរបស់ខ្លួននោះឡើយ ។

### គ. ស.

Buddhist Institute



## ៦ ដើមអម្ពិលទឹក

១- គេកាត់គេច្រិបគេរក្សា

ស្អិតស្អាងកាយាឱ្យ ឥតហ្មង

ពីខាង ពីលើ ផ្ទៃរបង

អ្នកផងសរសើរអម្ពិលទឹក ។

២- ថាជារុក្ខជាតិមានវាសនា

គេរាប់ប្រើការបានសន្ទឹក

មានដើមមានមែកបន្លាញឹក

សន្ទឹកក៏ស្រស់រស់យូរយារ ។

៣- តែស្រស់តែស្អាតតែត្រឹមត្រង់

រូបខ្ទង់នេះសម្រាប់នរណា ?

សម្រាប់អម្ពិលទឹករុក្ខា?

ឬថាសម្រាប់មនុស្សវិញទេ? ។

៤- ដើមណាដែលរស់តាមធម្មជាតិ

លូតលាស់តាមមាឌមែកទន់ទេរ

សារិកាច្រៀវច្រៃច្រៀងបំពេរ

Buddhist Institute



ផ្កាផ្លែរាំរេតាមសូរខ្យល់ ។

៥- ឯដើមឈើរត្រៀបតម្រៀបជួរ
សមគួរល្អគន់ពន់ពេកសល់
តែកំរើកដែកន្ត្រៃដល់
បានផលដាច់កត្រដររស់ ។

៦- រស់រាប់ខែឆ្នាំចាំជីវិត
ក្រិនក្រៀមក្រពឹតឥតកម្ពស់
យាមផ្ទះឱ្យគេទទេសោះ
មានឈ្មោះតែត្រង់គេថាល្អ ។

៧- លុះថ្ងៃដែលប្រាក់កាលគេដល់
គេកាប់គ្មានសល់ពូជទុកត
គេគាស់ទាំងឫសចាក់គ្រឹះថ្ម
គេសរសើរល្អរបងដែក ។

ភ្នំពេញ ១៨ មេសា ១៩៦៥

Buddhist Institute



# "បទុមសុរិយា" ផ្សាយរូប

១- បទុមសុរិយា ផ្សងរូបប្រាថ្នា
រើសរកស្វាមី បានព្រះជិនវង្ស
តាមរករូបស្រី ដល់ក្រុងអស៊ី
រួមរស់ស្នេហា ។

២- ក្រមុំសម័យ រាងរៀវច្រវៃ
បង្ហាញភក្ត្រា ញញឹមប្រិមប្រិយ
លើក្របទស្សនា- វដ្ដីកាលណា
ខ្ញុំលួចកើតទុក្ខ ។

៣-ខ្ញុំសែនស្នេហា ចង់ផ្សងវាសនា
ឱ្យបានជួបមុខ ទាស់ពីគ្មានឫទ្ធិ
ឬគ្មានទ្រព្យស្ដុក ក្រែងស្រីមិនសុខ
ចិត្តចងស្នងស្នេហ៍ ។

៤- ម្យ៉ាងទៀតរូបស្រី ផ្សាយពេញផែនដី
បុរីនៃខ្មែរ មិនតែរូបមួយ
ខ្ញុំព្រួយគ្មានល្បែ ក្រែងមានគេដែរ

Buddhist Institute



ផងចិត្តប្រចណ្ឌ

៥- នាំកើតច្បាំងគ្នា ដូចជាក្រុងមារ
យក្សសាលីកណ្ឋ អួតអាងរាល់ខ្លួន
គំគួនដុកដាន់ ខ្ញុំមិនគួចកាន់
សូមដកខ្លួនថយ ។

ភ្នំពេញ ១៩ មេសា ៦៨

Buddhist Institute



# ទំព័រសៀវភៅ

## ទំព័រជីវិត

១- ពេលដែលខ្ញុំបើកទស្សនា-
វដ្ដី កាលណាខ្ញុំសប្បាយ
មើលរូបភ្លើតភ្លើនភ្លេចឃ្លានបាយ
រីករាយស្រស់ស្រាយហក់តាមខ្យល់ ។

២- មើលឡានចេញថ្មីល្បីថាឆើត
ខ្លួនវែងរាងស្ដើតទើបមកដល់
បើត្រូវឆ្នោតធំសមលែងខ្វល់
ទិញមួយហើយសល់លុយដើរលេង ។

៣-មើលម៉ូដទំនើបធ្វើសក់ថ្មី
ទឹកមុខលោកស្រីស្រស់ថ្លាឈ្វេង
ថតបែរមុខក្រោយថែមស្អាំឆ្វេង
ខ្ញុំមុខជាគេងស្រមៃហើយ ! ។

៤- មើលតារាឯកនៃភាពយន្ត

Buddhist Institute



ល្អគយល្អគន់ណាស់លោកអើយ
ចេះធ្វើឬកពាចេះឆ្លងឆ្លើយ
ឃើញហើយជាប់ចិត្តឥតចង់ឃ្លាត ។

៥- មើលការប្រឡងភាពសង្ហា
សង្ហាអស្ចារ្យថែមឡានទៀត
ធ្វើឬកធ្វើរាងចែកជូនញាតិ
បំណាច់ខំឆ្លៀតមកពីឆ្ងាយ

* * *

៦- ក្នុងរូបអី ៗ សុទ្ធតែល្អ
ក្លឹងខ្មៅអាចសទៅវិញបាន
ខ្ញុំចង់មើលរូបទាំងប៉ុន្មាន
កំសាន្តសប្បាយឆ្ងាយជីវិត

ក្រុងតាកែវ ២១ សីហា ៦៥

Buddhist Institute



## សួនឧទ្យាន

១- វង់ ៧ មនុស្សជុំជិត
ជីវិតភ្លើតភ្លើនភ្លេចក្នុងបារ
បទភ្លេងល្វេងល្វើយដាស់កាមា
សួនច្បារផ្ការីកពេលរាត្រី ។

២- ផ្ការីកស្គុះ ៧ ក្នុងភ្លើងពណ៌
អប្សររេរាំតាមតន្ត្រី
ចម្រៀងល្ហិមល្ហែមផ្អែមសម្តី
ស្រស់ស្រីនាងជាទេពកញ្ញា ។

៣-កំសាន្តក្នុងសួនទិព្វវិមាន
ចិត្តគ្មានកង្វល់ដល់ទុក្ខា
រសាត់បាត់ហើយរឿងខ្លោចផ្សា
ចិន្តាចាំចង់តែថ្លើមថ្លៃ ។

៤- ភ្លេចភ្លាំងអស់ហើយការសិក្សា
ភ្លេចហើយគ្រួសារជាប់ជើងដៃ
ភ្លេចហើយទុក្ខសោកអ្នកដទៃ

Buddhist Institute



គិតលៃម្ដេចបានប្រាក់រាំបារ ។

៥- អ្នកណាងាប់រស់អ្វីក៏ដោយ

គិតឱ្យតែអញបានហ៊ុំហា

ផឹកស៊ី ស៊ីផឹក ផឹកសង្ការ

កំសាន្តសួនច្បារផ្កាងងឹត ។

ភ្នំពេញ ២៤ មិថុនា ៦៥

Buddhist Institute



# សីលធម៌ស៊ុំញៀម

១- ផ្ទះថ្មល្អហួសពីការស្មាន
ក្បែរផ្ទះមានឡានចតសេសសល់
ម្ចាស់ផ្ទះឈរស្ទើតមើលមកផ្ដល់
ចុះផលបុណ្យអ្វីរបស់គេ !

២- ឡានតូចថ្មីថៃសបើកដំបូល
ចេញចូលលួនលេងគ្មានទំនេរ
ថ្ងៃល្ងាចលោកប្រុស-ស្រីទាំងទ្វេ
សង្ហាម៉្លេះទេគេធ្វើអ្វី ?

៣- ទំនិញទំនើបពីបរទេស
សុទ្ធល្អវិសេសផុតដែនដី
គេតែងនិយមទាំងប្រុសស្រី
ធ្វើអ្វីបានប្រាក់ទិញដូចចិត្ត ?

៤- ភាពយន្តទំនើបបង្ហាញច្បាស់
ឃើញណាស់តែអ្វីដែលប្រណីត
ខ្លួនក្រចិត្តល្ងួតហួសកំហិត

Buddhist Institute



តើគិតម្ដេចផ្គាប់ស្កប់តណ្ហា ?

៥- បារមានហូរហែរពេញទីក្រុង
រាំឱបចិត្តស្នូងក្នុងកាមា
គិតម្ដេចឱ្យតែបានស្រីស្រា
នរណោរស់ស្លាប់កុំខ្ចីខ្វល់ !

៦- រង្វើរមួយណាក៏ផ្កាស្រស់
ផ្ការីកទាំងអស់ឥតសេសសល់
ឱ្យតែផ្គាប់ចិត្តផ្កាជិតដល់
ខ្វះលុយកុំឆ្ងល់ចៀសឱ្យឆ្ងាយ !

៧- ផ្ទះថ្ម . ឡាន. កុន. បារ. ស្រស់ស្រី
ឋានសួគ៌លោកិយសែនសប្បាយ
សង្ឃឹមប្រាក់ខែម្ដេចគ្រប់ចាយ
ត្រូវតែខ្វល់ខ្វាយខំ " រកស៊ី " !

៨- ឱសីលធម៌អើយ ! អ្នកកុំច្បាំង
តតាំងម្ដេចឈ្នះឆោមនារី
អញ្ជើញដកខ្លួនចូលគម្ពីរ
ទុកទីជូនទៅទេពតណ្ហា ។

ភ្នំពេញ ២៤ មិថុនា ៦៥

Buddhist Institute



# សុរិយាក្តៅខ្លាំង

១- សុរិយាល្ងាចថ្ងៃ ទន្សោងគោព្រៃ
រកស៊ីជើងភ្នំ តូចស៊ីតាមតូច
ធំស៊ីតាមធំ រកស៊ីជើងភ្នំ
ល្បាស់ព្រៃចខ្ចី ។

២- សុរិយាល្ងាចថ្ងៃ យុវជនសម័យ
ចង់ធ្វើតន្ត្រី ព្រោះឃើញគេមុន
ប្រពន្ធពីរបី ផ្ទះថ្មឡានថ្មី
មិនបាច់ខិតខំ ។

៣-សុរិយាល្ងាចថ្ងៃ មនុស្សលោកសម័យ
យកលុយជាធំ លុយជាចៅហ្វាយ
ប្រសើរឧត្តម ដឹកក្បាលឱ្យខំ
និយមតែលុយ ។

ភ្នំពេញ ១៣ កក្កដា ៦៥

Buddhist Institute



# សំណើចចំអកនៃទឹកប្រាក់

១- សាមគ្គី, សុចរិត, យុត្តិធម៌
មនុស្សធម៌, សីលធម៌, "ធម៌" ច្រើនណាស់
សរសេរហូរហៀរលើក្រដាស
ស្លាប់ពួកក្រៃក្រោសក្នុងសម្ដី ។

២- "ធម៌" នេះចេញមុខអើតមាត់ទ្វារ
បង្ហាញឫកពាស្រស់ប្រិមប្រិយ
រាប់រក "មិត្តភាព" រក "មេត្រី"
សេពគប់ "ប្រណី" គប់ "ករុណា"

៣- ខាងក្នុង "ទឹកប្រាក់" វាសប្បាយ
លួចសើចក្អាកក្អាយចំអកថា :
"អាប្រាក់ ! អញនេះហើយខ្លាំងក្លា
សោយរាជ្យចេស្ដា លើក្បាលមនុស្ស" ។

ភ្នំពេញ, ៤ កក្កដា ៦៥

Buddhist Institute



# "ទិលទិញឬអូន ?"

១- តូច-ធំ ធំ-តូច ស្ដួច-រីកសាយ ចង្អៀត-ទូលាយ រួចចង្អៀត
វែង- ខ្លី ខ្លី-វែង រួចខ្លីទៀត រួចបង្ហាញចង្កេះឱ្យច្បាស់ការ ។

២-ពីដើមមនុស្សស្រោតរួចចេះប៉ិង រួចប្រឹងដេរស្លៀកបិទកាយា
ស្លៀកពាក់ជុំជិតរឹតអាត្មា យល់ថាបែបហ្នឹងទើបហៅល្អ ។

៣-ឥឡូវយល់ថាវែងលែងសម តាំងខំរៀលរះបញ្ចេញបញ្ចូក បង្ហើច
ដល់ភ្លៅនៅបន្ដ ចំហរថែមទៀតជូនកំសាន្ដ ។

៤- យូរទៅប្រហែលជាគេប៉ិង ឬស្រោតទេដឹង? មិនហ៊ានស្មាន !
យ៉ាងណាក៏ដោយឱ្យតែបាន តាមដានសម័យថ្មីឱ្យទាន់ !

ភ្នំពេញ ១២ កក្កដា ៦៥

---

**សូមរង់ចាំអាន ! . . . .**

**"សុខវិធីនៃជីវិត"**

ដែលជាសៀវភៅប្លែក ស្ដីពីទស្សនវិជ្ជាបែបសង្គម សា
ស្ដហើយប្រទេសយើងពុំទាន់មាន . . . ជារង្វាន់នៃរបប
សាធារណរដ្ឋខ្មែរផ្សាយចេញនៅដើមខែធ្នូនេះហើយ អរគុណ ។

**ពីមិត្ត គង់-វឌ្ឍា**

Buddhist Institute



# ខ្ញុំតាមមិនទាន់

១- កញ្ឆែច ! កញ្ឆែច ! ភ្លេងសម័យ
កន្ត្រាក់សរសៃឱ្យរាំរែក
អន្ទងបេះដូងឱ្យយំយែក
ហាក់ស្រែករកស្រីស្រៀវកាមា ។

២- គេឱប គេរឹត គេត្រកង
បែរមុខវិលខ្នងពត់កាយា
គេងើប គេមុជ ក្រោមហត្ថា
ហ្មឹងហើយសូត្រានាលោកីយ ។

៣- កុំអួសដៃខ្ញុំធ្វើអីមិត្ត
រាំចុះកុំគិតខ្ញុំធ្វើអ្វី ! . .
ខ្ញុំមិនចេះរាំក្បាច់ខ្មែរថ្មី
ព្រោះអីខ្ញុំដើរមិនទាន់គេ ។

៤- និស្ស័យនៃខ្ញុំអស់ផ្លូវកែ
ខ្ញុំកើតនៅស្រែឥតចេះទេ
ខ្ញុំរស់នៅវត្តស្ទូតបំពេរ

Buddhist Institute



បញ្ញានរាំលោកដេរវាយបែកខ្ទង ។

៥- កំហុសយ៉ាងធំ ! ខ្ញុំមិនកែ
ទើបងើបពីស្រែស្គាល់ក្រុងម្តង
ទើបចេញពីវត្តផុតរបង
ម្តេចឡើយប្រឡងរាំញ៉ូវញាក់ ។

៦- កំហុសយ៉ាងធំ ! ខ្ញុំមិនកែ
ខ្ញុំខ្មែរភ្លេចស្រែរាំកន្ទ្រាក់
ខ្មាសម៉ែ-ឪ-មា-មីងមិត្តភក្តិ
ខ្មាសបាយបាត្រស្រោក់ខ្មាសខ្លួនឯង ។

ភ្នំពេញ ១៨មេសា ៦៥

Buddhist Institute



# អតីតពួកម្លោះស្រុកស្រែ

១- ពីដើមនៅស្រុកស្រែចម្ការ
ស្នេហាសុខដុមភិរម្យណាស់
ក្រមុំកម្លោះស្មោះស្ម័គ្រច្បាស់
ទាំងចាស់ទុំក៏ព្រមលួមចិត្ត ។

២- ស្រឡាញ់គ្នាពិតឥតបែកបែរ
ឥតប្រែប្រុងប្រាសផ្តាសចោលមិត្ត
គិតតែរកស៊ីសាងជីវិត
សុចរិតត្រឹមត្រង់សាងក្តីសុខ ។

៣- ឥឡូវក្រមុំចម្ការស្រែ
ចិត្តប្រែចោលកម្លោះក្នុងស្រុក
ខំខិលដាំដកស្ទូង ចង់ស្រណុក
ចាក់ស្មុគរកស្ម័គ្រអ្នកប្រាក់ខែ ។

៤- កម្លោះស្រុកស្រែបែរអន់អៀន
ខ្លួនគ្មានបុណ្យសក្តិធ្លាក់ភ្នួរស្រែ
ម្តេចឡើយគេនឹងមកស្និទ្ធស្នេហ៍
ម្លោះហើយត្រូវតែរស់ក្រៀមរកំ ។

ភ្នំពេញ ២៥ មិថុនា ៦៥

Buddhist Institute



# ប្រតិភូក្បត់ពូជ

១- អ្នកក្រត្រដរឱ្យកូនរៀន
ខំប្រឹងស្ទើរលៀនភ្នែកគ្រប់គ្នា
លក់គោក្របីជ្រូកមាន់ទា
ដីស្រែចម្ការសឹងមិនសល់ ។

២- កូនខ្លះផ្តេសផ្តាសមិនខំរៀន
ថែមហ៊ានយកលុយម៉ែឪផ្តល់
ចាយវាយហ៊ឹកហាក់ហាក់តាមខ្យល់
មិនមានគិតដល់ញើសឪម៉ែ ។

៣- កូនខ្លះគ្រាន់បើខាងរៀនសូត្រ
ស្មុះលូតរបួតផុតដីស្រែ
ធ្វើការរាជការបានប្រាក់ខែ
ប៉ុន្តែភ្លេចអស់រឿងក្រីក្រ

៤- ភ្លេចពូជពណិពង្សវង្សអធន
ដែលរងទុក្ខធ្ងន់មកច្រើនត
ត្រូវគេព្រួតគ្នាច្របាច់ក

Buddhist Institute



គ្រដររកខ្យល់ចាំតែស្លាប់ ។

៥- អ្នកក្របញ្ជូនឱ្យមករៀន
ឱ្យមានតម្រិះចេះប្រញាប់
ភ្នែកភ្លឺឃើញច្បាស់ឱ្យដាស់ប្រាប់
ម្ដេចឡើយក្រឡាប់ក្បត់ពូជឯង ។

៦- បែរជាព្រួតដៃនិងអ្នកខ្ពស់
ទ្រគោះប្រឆាំងច្បាំងកំហែង
ថាក្រពោះខ្វិលមិនប្រឹងប្រែង
ថាកម្មតាក់តែងពីព្រេងនាយ ។

៧- បើតែម្លឹង១អ្នកខ្សោយខ្សត់
ប្រាកដជាគ្មានផ្លូវដោះស្រាយ
គេក្បត់ខ្លួនអស់ព្រោះជិនណាយ
ព្រោះគេសប្បាយភ្លេចពូជពណ៌ ។

ភ្នំពេញ ២៤ កក្កដា ៦៥

Buddhist Institute



# ក្រឡាស់ចិត្តនេះដឹង ?

១- ខ្លួនក្រចិត្តខ្ញុំក៏អ្នកក្រ
ឃើញមិត្តពលករខ្ញុំអាណិត
ឃើញក្មេងស៊ីឈ្នួលខ្ញុំខ្លោចចិត្ត
តែងគិតឈឺឆ្អាលជួយឈឺចាប់

២- សព្វថ្ងៃ ខ្ញុំខំសាងវាសនា
សង្ឃឹមថ្ងៃណាទោះយូរឆាប់
ថាក្រគងផ្លាស់ច្បាស់ក្រឡាប់
ប្រញាប់ព្រួយថ្វីនៅ " ក្មេង" ដែរ (១) ។

៣- ចង់គ្រាន់ តែខ្ញុំបារម្ភណាស់
ក្រែងចិត្តខ្ញុំផ្លាស់ក្រឡាស់ប្រែ
ចូលដៃក្រុមនោះដូចគេដែរ
រួចបែរគ្រហឹមដាក់មិត្តចាស់ ។

៤- ប្រសិនគ្រប់គ្នាតែបែបហ្នឹង
រៀនសូត្រចេះដឹងចិត្តក្រឡាស់
មិនបើកភ្នែកគ្នាឱ្យឃើញច្បាស់

Buddhist Institute



ស្រឡះតែម្តងអស់ផ្លូវហើយ ! . . .

ភ្នំពេញ ២២ កក្កដា ៦៥

X X X

---

(១) ស្រីហិតោបទេសថា ៖ បើរកទ្រព្យ-រកវិជ្ជាត្រូវគិតថាខ្លួនមិនចាស់ មិនស្លាប់, បើរកធម៌ត្រូវគិតថាខ្លួនត្រូវម្រឹត្យុក្របួចសក់បោកសម្លាប់ឥឡូវហើយ ។

Buddhist Institute



# ឱ្យខ្ញុំសប្បាយដូចម្ដេចកើត ?

១- នៅក្រុងខ្ញុំឃើញគេសប្បាយ
សម្បូណ៌ប្រាក់ចាយឫកហ៊ឺហា
ឡានថ្មីផ្ទះថ្មល្អស្កាវស្ការ
កូនល្មោនស្រីស្រោរស្រើបច្រៀងរាំ ។

២- មកស្រែខ្ញុំឃើញអ្នកស្រុកក្រ
ខ្វះស្រូវអង្ករត្រដររខំ
រកត្រីបន្លែជូញដូរផ្សំ
នឿយហត់ក្រៀមក្រំព្រោះអត់ឃ្លាន ។

៣- ឆ្ងាយណាស់ ! ឆ្ងាយដូចដីនឹងមេឃ
ឆ្ងាយពេកវាងក្រនិងមាន
កាលណាទើបទេវតាប្រទាន
ឱ្យមនុស្សសុខសាន្តប្រហែលគ្នា ?

ក្រុងតាកែវ ២២ សីហា ៦៥

Buddhist Institute



**<<នគរថ្មើងថ្មែក សប្បាយតែភ្នែក**

**ក្នុងចិត្តរងកម្ម>>** ( ក្រុមង៉ុយ )

១- នគរថ្កើងថ្កានបានចម្រើន
ផ្ទះថ្មក៏ច្រើនលូតកប់មេឃ
រថយន្តតូចៗច្រើនជ្រុងពេក
មនុស្សដេក "ផ្សងព្រេង" ក៏ច្រើនដែរ ។

២- អ្នកមាន មានស្តុកទ្រព្យក្រៃក្រាស់
អ្នកក្រ ក្រណាស់ខ្វះគ្មានល្ហែ
អ្នកមានទិញសាច់គោឱ្យឆ្កែ
អ្នកស្រែម្ចាស់គោស៊ីប្រហុក ។

៣- កូនលោកអ្នកមានរៀនសាលា
សប្បាយហ៊ឺហារីតរីកមុខ
កូនសិស្សក្រខ្សត់ខ្វះស៊ីចុក
កើតទុក្ខខ្វះលុយបង់សាលា ។

៤- អ្នកខ្យល់ត្រូវក្តោងបោងហោប៉ៅ

Buddhist Institute



ហិចហើរហក់ទៅផ្លូវបនបារ
អ្នកប្រាក់ខែ "ងាប់" គេរាប់ថា
ជាមនុស្សយ៉ាបឆាខ្វះអង្ករ ។

៥- សប្បាយមែនហើយលោកអ្នកមាន !
អ្នកក្រវ៉ាល់លានតឹងណែនក
ខំស្ទីតរកខ្យល់ស្ទឹងភ្នែកស
ត្រដរស្រែកថា "សប្បាយណាស់ !" ។

ភ្នំពេញ ២៤ កក្កដា ៦៥

Buddhist Institute



# ទំនិញក្រមអូ

១- ផមូជាតិដែនដូងចិត្តកវី
សប្បាយនឹងដីវែងអន្លាយ
នឹងទឹករលករលាមសាយ
នឹងមេឃខ្ពស់ឆ្ងាយដូចឆ្ងាយស្នេហ៍ . . .

២- តាង៉ុយកវីប្រជាជន
ចិត្តផ្ទន់លើវាស្រ្តចម្ការស្រែ
ស្រឡាញ់ពេញចិត្តតែជាតិខ្មែរ
ទូន្មានគ្មានល្ហែឱ្យភ្ញាក់ខ្លួន

៣- ឥឡូវលោកតាសម្រាកហើយ
ម្ដេចឡើយសម្រាកក្បែរចិនយួន
រោងកុន ផ្សារដែក សម្រែកផ្ទួន
ជួបជូនសួរស័ព្ទអាប់ខ្សៀវខ្វា

៤- នេះឬរង្វាន់នៃកវី
មានប្រជាប្រិយពេញរដ្ឋា
រង្វាន់លាក់ខ្លួនពួនអំរាត្វា

Buddhist Institute



នៅកណ្ដាលផ្សារគ្មានគេស្គាល់ ។

ភ្នំពេញ ១២ កក្កដា ៦៥

**កំណត់ចំណាំ :**

ឈ្មោះផ្លូវតូចមួយម្រាប់ក្រមង៉ុយ ឈ្មោះវិទ្យាល័យមួយ និង សាលាបឋមសិក្សាមួយសម្រាប់ម៉ូនិក ។

(កំណត់សរសេរថ្ងៃ ១២-១១-៧០)

វិទ្យាស្ថាន
LIBRARY
BUDDHIST INSTITUTE

Buddhist Institute



# តិចឬច្រើន ?

១- ចៅអើយ រូបតាប្រាថ្នាតិច !
ទ្រព្យធនបេះបិចលះជាទាន
បរិច្ចាគអស់ហើយលែងចង់មាន
ដូវសួគ៌និព្វានឋានសុខា

២- តាអើយ រូបចៅប្រាថ្នាច្រើន !
ក្រវើនខ្ជីឃ្មាតសព្វកិច្ចការ
ចង់មានតែក្នុងលោកនេះណា
មិនមានប្រាថ្នាសួគ៌និព្វាន ។

ភ្នំពេញ ១៩ មេសា ៦៥

Buddhist Institute



# ព្រះសង្ឃនិមន្តបិណ្ឌបាត្រ

១- នៅតាមស្រុកស្រែស្រុកចម្ការ
លេចតាមរុក្ខាមើលឃើញច្បាស់
ពណ៌លឿងភ្លឺថ្លាល្អត្រចះ
ឃើញហើយចិត្តជ្រះថ្លាបំផុត ។

២- ព្រះសង្ឃនិមន្តបិណ្ឌបាត្រ
ឃើញសមស្អាង ស្អាតបរិសុទ្ធ
គួរនឹកដល់អង្គព្រះសម្ពុទ្ធ
ជាមកុដកំពូលសីលធម៌ ។

៣- នៅតាមទីក្រុងមនុស្សជោរជាន់
ព្រះសង្ឃនិមន្តត្រាច់គោចរ
បិណ្ឌបាត្រតាមផ្លូវដ៏អ៊ូអរ
ឃើញហាក់មិនល្អមិនសមសួន ។

៤- ព្រះសង្ឃនិមន្តផ្ទាល់លើដី
អស់លោកប្រុសស្រីខ្មែរចិនយួន
សុទ្ធយានជិនិះជិះរៀងខ្លួន

Buddhist Institute



គាប់ជួនពេលខ្លះចង់ប៉ះផង ។

៥- ហ្នឹងហើយក្រុងធំមនុស្សថ្កុំថ្កើង
ខ្ពង់ខ្ពស់ខ្លាំងឡើងជាចម្បង
នៅស្រែមនុស្សល្ងង់ទាបកន្លង
តែសមគ្មានឆ្លងក្នុងឥរិយា ។

ក្រុងតាកែវ ២៥ សីហា ៦៥

Buddhist Institute



# សម្រាកមួយភ្លែត

១- ឈប់សិន ! ឈប់សិន ! វិទ្យាសាស្ត្រ
លឿនណាស់ ! លឿនណាស់ ! ចក្រអ្នកឯង
ខ្ញុំខំផាយតាមហត់ហួតហែង
សុំឈប់ប្រជែងផ្អាកចលនា ។

២- ខ្ញុំក្រាលស្លឹកឈើក្រោមម្លប់ស្វាយ
ដាក់កាយទម្រេតកើយក្រមា
ខ្យល់បក់ល្មៀក១ល្ហើយកាយា
ចិន្តាហោះហើរហិចទៅឆ្ងាយ . . . ។

៣- កាលដើមចង្វាក់នៃជីវិត
ហាក់ឥតរន្ធើនក្ដៅក្រហាយ
រង្វើល ១ លយអន្លាយ
សប្បាយហូរហែរតាមធម្មតា ។

៤- រទេះទឹមគោបរង៉េតង៉ត
ត្រេតត្រតទ្រុយ ១ កាត់ព្រៃក្បា
សូរស័ព្ទសត្វយំឆ្លងឆ្លើយគ្នា

Buddhist Institute



កំព្រាដូងចិត្តដូចនេនទុំ ។

៥- ឯនាយដងទង់ចុងជញ្ជា
ដំបូលវិហារកុដិមួយដុំ
លេចតាមចន្លោះដើមឈើជុំ
មើលឃើញជ្រុងជ្រងសមជ្រះថ្លា ។

៦- ឯនុំះដំណែលប្រាង្គប្រាសាទ
ស្អាងស្អាតសុទ្ធសឹងក្បាច់សិលា
មិនដឹងប៉ុន្មានតដូនតា
ឥឡូវព្រឹក្សាដុះព័ទ្ធព័ន្ធ. . .

ភ្នំពេញ ៣ កក្កដា ៦៥

---

៧- កាលគ្មានទឹកកកមនុស្សគិតថា
ផឹកទឹកស្រះថ្លាឆ្ងាញ់ណាស់ហើយ
កាលគ្មានឡានលឿនមនុស្សព្រងើយ
ដើរលេងរំហើយគ្មានប្រញាប់ ។

៨- ក្រុងរីកធំឡើងត្រូវទិញខ្យល់

Buddhist Institute



ទិញសព្វគ្មានសល់គ្រប់ប្រដាប់
ទិញណាស់ខ្វះណាស់ខ្វល់ស្ទើរស្លាប់
ស៊ីណាសរីតឆាប់ឃ្លានមកវិញ ។

៩- ចម្រើន សម្រាប់តែចម្រើន
គិតទៅគ្មានកើនលើសជាថ្មី
ខំលូតនាំហាត់អត់បានអ្វី
គួរតែលែងខ្ចីរត់តាមទៀត ។

ក្រុងតាកែវ ២២ សីហា ៦៥

Buddhist Institute



## រកស្រប់គេថាចាញ់

១- ខំរក រកណាស់ រឹតខ្វះណាស់
ខំរៀនដល់ចាស់នៅមិនចប់
បាននេះច្រូះនោះមិនចេះសព្វ
មិនស្កប់តណ្ហាមនុស្សសម័យ ។

២- ចង់ដកខ្លួនថយរស់ដោយព្រៃ
ជីវភាពប្រែពៃសប្បាយក្រៃ
រស់តាមធម្មតាជាតិរាល់ខែថ្ងៃ
ចិត្តលែងចង្រៃអន្ទះសា ។

៣- តែធ្វើដូច្នេះគេថាចាញ់
មិនខ្មេះរត់ខ្លាញ់ពួនអាត្មា
ថែមគេមើលងាយនិយាយថា:
វាអន់បានជានៅក្នុងព្រៃ ។

ភ្នំពេញ ២៣ កក្កដា ៦៥

Buddhist Institute



# អាសូរដើមដូង

១- យូរហើយដូងដុះក្នុងភូមិម្ភ
ដើមធាងល្អូតល្អមានផ្លែផ្កា
ស្រាប់តែគេផ្តាច់ឫសផ្តាច់អាហារ
គេថាគាស់ជីកយកទៅដាំ ! ។

២- ល្ងាចនេះដូងដុះក្បែរសាលា
លោកអ្នករាជការខំថែទាំ
តុបតែងស្រោចទឹកយ៉ាងជោគជាំ
ផ្ទាក់ផ្ទមមុតមាំខ្លាចដូងដួល ។

៣- ព្រឹកឡើងបុណ្យសម្ពោធសាលា
មនុស្សមូលខ្សៀវខ្វាមីរខ្វាញ់ខ្វល់
ញញឹមប្រិមប្រិយចាំទទួល
ស្រុះស្រួលចោមជុំសម្តេចឪ ។

៤- ដើមដូងដាច់ឫសសប្បាយដែរ
រេរាំហូរហែតាមក្បែរផ្លូវ
ញញឹមស្វាគមសម្តេចឪ

Buddhist Institute



មើលអស់លោកត្រូវបានមេដៃ ។

៥- ព្រឹកដីរកកាយកន្លងទៅ

ដូងនៅម្នាក់ឯងកណ្ដាលថ្ងៃ

សូរ្យសែងក្ដៅដុតគ្មានសំចៃ

ដូងក្សំយចោលរូបកណ្ដាលក្រុង ។

ភ្នំពេញ ១២ កក្កដា ៦៥

Buddhist Institute



# ស្តាយដួងចន្ទ្រា

១- ខ្ញុំស្រឡាញ់ដួងចន្ទ្រាពេញបូណ៌មី
រឿងរង្សីភ្លឺត្រចះច្បាស់មេឃា
ស្អាតបរិសុទ្ធមូលក្រឡង់ក្នុងនភា
ខ្ញុំនិន្ទ្រាមិនលក់ឡើយពេលរាត្រី ។

២- ខ្ញុំស្រឡាញ់ដួងចន្ទ្រាភ្លឺត្រជាក់
ពន្លឺប្រាក់ស្រោបដួងចិត្តជនប្រុសស្រី
ឱ្យសប្បាយភ្លើតភ្លើនចិត្តឥតខ្វល់អ្វី
ភ្លេចក្រក្រីក្តីសោកសៅក្នុងជីវិត ។

៣- ខ្ញុំស្រឡាញ់ដួងចន្ទ្រាមូលក្រឡង់
ហាក់ដូចវង់ភក្រ្តកល្យាណគូស្នេហ៍ស្និទ្ធ
នាងញញឹម ខ្ញុំសង្ឃឹម សប្បាយចិត្ត
ហាក់បានជិត រីតរូមរក្ស ស្ម័គ្រកនិដ្ឋា ។

៤- ខ្ញុំស្រឡាញ់ដួងចន្ទ្រាជាសាក្សី
នៃសេចក្តីស្មោះស្ម័គ្រចិត្តស្និទ្ធស្នេហា
នៃក្រមុំ និងកម្លោះគូសង្សារ

Buddhist Institute



ដែលប្រាថ្នាបានជាតួរូបរូមកាយ ។

៥- ខ្ញុំស្រឡាញ់ដួងចន្ទ្រាជាល្បែងក្មេង
ម្ដាយពោលលេងឱ្យកូនតូចពនសុំបាយ
សុំសម្ល . ទឹកបំពង់ . ចេក . ដូង . ស្វាយ
កូនសប្បាយញ៉ាំចិប ៗ សើចក្អឹក ៗ ។

៦- ខ្ញុំស្រឡាញ់ដួងចន្ទ្រាមានពោធិធំ
ជីដូនខ្ញុំប្រាប់ដូច្នេះមកជាញឹក
មើលទៅឃើញមានឫសគល់ដើមមែកស្លឹក
ក្រោមពោធិព្រឹក្សដូនចាស់រវៃអំបោះ ។

៧- ខ្ញុំស្រឡាញ់ដួងចន្ទ្រាហៅសសាង្ក
ព្រះឥន្ទ្រស្នាងរូបទន្សាយទុកនៅនោះ
រំលឹកកាលពោធិសត្វគិតសង្គ្រោះ
ព្រាហ្មណ៍ដោយស្មុះលោតចូលភ្លើងជាអាហារ

៨- ខ្ញុំស្រឡាញ់ដួងចន្ទ្រាហៅលោកខែ
នៅស្រុកខ្មែររាជពិធីដ៏ថ្លៃថ្លា
អកអំបុកងើយមើលចំដួងចន្ទ្រា

Buddhist Institute



បន់ទេពតា សូមខេមរាបានថ្កើងថ្កាន ។

៩- ខ្ញុំស្រឡាញ់ដួងចន្ទ្រានៃកវី(១)
ក្នុងរាត្រីនាំអារម្មណ៍ឱ្យក្សេមក្សាន្ត
ខ្លួនរំភើបបាក់អណ្តែតទៅឆ្ងាយបាន
ភ្លេចខ្លួនប្រាណសប្បាយតាមការស្ទី ។

១០- ខ្ញុំតូចចិត្តនឹងពួកអ្នកវិទ្យាសាស្ត្រ
ម្តេចក៏ផ្តាសធ្វើកាំជ្រួចបាញ់ពីដី
ចង់ទៅយកដួងព្រះចន្ទ ពិភពថ្មី
ហេតុចង់ល្បីខ្ចាយកេរ្តិ៍ឈ្មោះបោះនាមា ។

១១- ខ្ញុំមិនចង់ឱ្យមនុស្សលោកសុទ្ធហ្មងសៅ
ដូចផ្សេងខ្មៅទៅប្រឡាក់ដួងចន្ទ្រា
ដែលបរិសុទ្ធផុតមន្ទិលផងនានា
គួរបូជាស្រឡាញ់ស្មោះពីហឫទ័យ ។

១២- ឱសែនស្តាយដួងចន្ទ្រាជាសាកល
ដែលតែងផ្តល់គ្រប់បំណងដោយប្រពៃ
ម្តេចឡើយអ្នកវិទ្យាសាស្ត្រគិតបំភ្លៃ

Buddhist Institute



យកចន្ទ្រថ្លៃជាកម្មសិទ្ធិឱ្យសៅហ្មង ។

(១) អត្ថបទតទៅនេះរហូតចប់ត្រូវបានសូត្រក្នុងពិធីចែករង្វាន់នៅវិមានរដ្ឋាភិបាល ។

ភ្នំពេញ ២៦ មិថុនា ៦៥

## ជីវិតនិស្សិត

ទំព័រខាងក្រោយតទៅនេះ ជាអត្ថបទកំណាព្យដែលខ្ញុំស្រង់ពីស្នាដៃទី ១ របស់ខ្ញុំឈ្មោះ "ជីវិតនិស្សិត" ។ ដូចខ្ញុំបានជំរាបអ្នកអានហើយថា ដោយស្នាដៃនេះខ្ទីពេក ខ្ញុំមិនបោះពុម្ពទេ ប៉ុន្តែខ្ញុំស្តាយអត្ថបទខ្លះដែលខ្ញុំស្រឡាញ់ ដូច្នេះបានជាខ្ញុំស្រង់អត្ថបទខ្លះនោះមកបញ្ចូលក្នុងសៀវភៅនេះផង ។

បើអត្ថបទទាំងនោះមិនមានប្រយោជន៍ចំពោះអ្នកអានទេខ្ញុំសុំគ្រាន់តែទុកវាសម្រាប់រំលឹកអនុស្សាវរីយ៍មួយទៅចុះ ។

គ.ស.

## នឹកផ្ទះ(១)

១- នៅសល់បីថ្ងៃ តែយូរពេកក្រៃ
បីថ្ងៃកើតទុក្ខ ជិតវាំកងហើយ
ម្តេចឡើយ "ជាប់គុក" គួរបានរីកមុខ
បានទៅកំសាន្ត ។

២-កំសាន្តសប្បាយ ជួបមិត្តទាំងឡាយ
ដែលយើងធ្លាប់បាន រស់ជាមួយគ្នា
នោះវិញមិនខាន ហៅសែនសុខសាន្ត
សម្រាន្តចិន្តា ។

៣-យើងកូនអ្នកស្រែ សប្បាយណាស់ដែរ
ប្រញាប់ម្ទីម្ទា វិលទៅស្រុកវិញ
ជួបមិត្តមីងមា ម៉ែឪយាយតា
គ្រួសាររីករាយ ។

៤- នឹងជួបមាន់ទា ជួប[illegible]
ដែលនៅឯនាយ ដែលធ្លាប់ស្រឡាញ់
ធ្លាបខឹងជេរវាយ [illegible]ទ្រាយ

Buddhist Institute



ដីស្រែឡើងវិញ ។

៥- តាអើយ ! រូបចៅ តាំងពីបែកទៅ
នៅឯភ្នំពេញ តែងនឹកមកតា
ឯទីនេះវិញ ទទូចទន្ទេញ
ចង់តែមកជួប ។

៦- យាយអើយ ! រូបចៅ តាំងពីបែកទៅ
អស់យូរខែខួប តែងនឹកមកយាយ
ចង់តែមកជួប ព្រោះខានបានរូប
រួមសំដីយូរ ។

៧- ឪអើយ ! កូននឹក ទាំងល្ងាចទាំងព្រឹក
បន់ឱ្យតែគ្រូ ឱយឈប់កាលណា
នឹងបានគិតគូរ មកផ្ទះឱ្យយូរ
ជួបជុំគ្រួសារ ។

៨- ម៉ែ ! ម៉ែ ! ម៉ែ ! ម៉ែ! កូននឹកគ្មានល្ហែ
បែកម៉ែថ្ងៃណា កូនស្រក់ទឹកភ្នែក
ទឹកម៉ែអស្ចារ្យ ម៉ែធ្លាប់រក្សា

Buddhist Institute



ផ្កាក់ផ្ទមរូបកូន ។

៩- ឯណាប្អូនខ្ញុំ ប្អូនតូចប្អូនធំ
បាត់ទៅណាសូន្យ អូ ! នោះមកហើយ
មក ! មក ! អាអូន បងនឹកមកប្អូន
ឯងរាល់គ្នាណាស់ ។

១០-តោយើងនៅទេ ? ទាំងកូនទាំងមេ
មេក្មេងមេចាស់ ចុះអាពពាល
តើវានឹកម្ចាស់ ដើមនៃវាខ្លះ
ដែរឬគ្មានទេ ។

១១-ឆ្កែបងអាល្វ ខានឃើញវាយូរ
ព្រោះគ្មានទំនេរ ខាននាំវាចេញ
ដេញសត្វដូចគេ ម្ល៉េះវាល្ងចជេរ
បងខ្លះទេដឹង ។

១២-ឯណារទេះ ដែលបងធ្លាប់ជិះ
មានចងកណ្ដឹង រទេះគោលឿន
បរបត់ក្បែរស្ទឹង រូចទៅក្បែរបឹង

Buddhist Institute



ទៅមើលស្រូវស្រែ ។

១៣-ម៉េចទៅឆ្នាំនេះ បានផលគ្រាន់បេះ
ច្រូតកាត់ខ្លះដែរ ឬមួយស្កកអស់
ពាសពេញទាំងស្រែ ដោយពីរបីខែ
គ្មានឃើញភ្លៀងសោះ ។

១៤-ទាំងក្រុមគ្រួសារ ទាំងញាតិកា
ឆ្កែឆ្មាទាំងអស់ ទាំងជ្រូកមាន់គោ
ខ្ញុំស្រឡាញ់ស្មោះ ចំពោះឥតខ្ចោះ
ជាងអ្វីនានា ។

១៥-ព្រោះអ្នកទាំងនេះ ដែលបានចេះរិះ
ទាំងអស់គ្រប់គ្នា ស្រឡាញ់ខ្ញុំពិត
ឱ្យមកសិក្សា ចំណេះវិជ្ជា
ជារស្មីប្រាពក ។

១៦-វិជ្ជាជាទ្រព្យ យ៉ាងប្រសើរគាប់
គួររកឱ្យបាន ត្រូវខំរៀនសូត្រ
ឱ្យចេះចំណេះ ថ្ងៃក្រោយទៅមុខ

Buddhist Institute



ក្បៀមក្សាន្តជីវិត ។

វត្តកែវព្រះភ្លើង . មេសា ៥៨

---

(១) កំណាព្យនេះកាលសរសេរខ្ញុំដាក់ឈ្មោះថា " គិតទុកបីថ្ងៃមុន" ឥឡូវខ្ញុំសុំកែឈ្មោះថា " នឹកផ្ទះ" វិញ ។ កំណាព្យនេះត្រូវបានសូត្រក្នុងពិធីចែករង្វាន់នៅក្នុងវាំង ។

Buddhist Institute



# លាការសិក្សា

១-សព្វថ្ងៃខ្ញុំភ្លើ ! អារម្មណ៍ខ្ញុំហើរ
ហោះហិចទៅឆ្ងាយ គ្មានទីកំណត់
កត់យកសប្បាយ ព្រួយចិត្តព្រួយកាយ
សំណាងមិនល្អ ។

២-ខ្ញុំនឹកសង្វេគ តែងព្រួយចិត្តពេក
ព្រួយព្រោះខ្លួនក្រ រៀនបានតិចតួច
ខំទាំងត្រដរ ឥឡូវនេះក៏
ត្រូវតែឈប់រៀន ។

៣-ចេញពីសាលា ចោលការសិក្សា
ចោលអស់របៀន លាអស់ពួកមិត្ត
លាគ្រូបង្រៀន លាទាំងគ្រឹះស្ថាន
ដែលធ្លាប់សិក្សា ។

៤-លាហើយណាមិត្ត ខ្ញុំលាអ្នកពិត
ចេញពីសាលា លាទាំងអាល័យ
ឥតបីនឹងថា ខ្ញុំត្រូវចាប់ការ

Buddhist Institute



ចិញ្ចឹមជីវិត ។

៥- ព្រោះខ្ញុំនេះក្រ គ្មានលុយបន្ត
ការសិក្សាពិត ត្រូវតែចាប់ការ
ចិញ្ចឹមជីវិត លាហើយណាមិត្ត
អ្នកនៅរៀនចុះ ។

៦- ខំទៅសំឡាញ់ រៀនយកឈ្នះចាញ់
ខំទាំងស្រីប្រុស ខំរៀនដើម្បី
ល្បាញល្បីកេរ្តិ៍ឈ្មោះ ត្រូវមិត្តខំលុះ
ទម្លុះអវិជ្ជា ។

៧- អវិជ្ជាគ្មានជោគ គឺជាមេរោគ
ចង្រៃមហិមា តែងស៊ីខួរក្បាល
មនុស្សគ្រប់គ្នា លុះតែស្មុះស្មា
រៀនទើបចៀសបាន ។

៨- វិជ្ជាជាថ្នាំ មិត្តអើយចូរចាំ
ខំរកឱ្យបាន ចៀសភាពល្ងិតល្ងង់
ដែលនាំថោកប្រាណ ទើបយើងនឹងបាន

Buddhist Institute



ជាពលរដ្ឋល្អ ។

៩- ខ្ញុំដឹងខ្លួនដែរ ខ្ញុំខំគ្មានល្ហែ
តែដោយខ្លួនក្រ រុលទៅមិនរួច
ព្រោះក្រីតក បានជាខ្ញុំចរ
ចាកការសិក្សា ។

១០-ខ្ញុំលាមិត្តទៅ ចិត្តខ្ញុំចាំនៅ
នឹងមិត្តគ្រប់គ្នា សង្ឃឹមជានិច្ច
ថាមិត្តមិនរា បំពេញវិជ្ជា
ទុកសម្រាប់ខ្លួន ។

១១-ឯរូបខ្ញុំវិញ ខ្ញុំពេញទោម្ញេញ
ដោយនឹកស្តាយខ្លួន រៀនមិនបានច្រើន
គ្មានចេះមាំមួន មិនបានសមសួន
ចំនួនចំណង់ ។

១២-តែទោះយ៉ាងណា ត្រង់ការសិក្សា
ខ្ញុំមិនលះបង់ ខ្ញុំខំរៀនទៀត
លុះត្រាអស់ចង់ សូមឱ្យមិត្តស-
ង្ឃឹមជឿខ្ញុំចុះ ។

ភ្នំពេញ, មេសា ៥៨

Buddhist Institute



# សម្រេចចិត្ត

១- គិតទៅគេងទៅនៅតែព្រួយ
ជីវិតខ្ញុំមួយគ្មានវាសនា
ជីវិតខ្ញុំមួយតើយ៉ាងណា
គ្មានបានសិក្សាច្រើនជ្រៅជ្រះ ។

២- គិតផងគេងផងគងថ្វាសគិត
ផ្ទះនៅមិនជិតរឹតឃើញផ្ទះ
ច្បាស់ណាស់ជីវភាពឃើញជាក់ច្បាស់
ក្រីក្រកម្មក្រាស់ពេញក្រក្រី ។

៣- ចិត្តអាណិតគ្រួសារខ្លោចចិត្ត
ស្ដីទៅព្រួយចិត្តមិនចេញស្ដី
ខ្ជីអស់គំនិតនាំគិតខ្ជី
ទ្រាំមិនគិតអ្វីស៊ូតែទ្រាំ ។

៤- រៀនពីរបីឆ្នាំពេលមករៀន
ក្រំក្រៀមឥតមានស្រោកក្រៀមក្រ
ខំណាស់ខាងរៀនស្គាល់ពីខំ

Buddhist Institute



រៀនដោយសន្សំខំប្រឹងរៀន ។

៥- គ្រូសារក្រណោស់ក្រមួយគ្រូ
គ្មានទ្រព្យល្អគួរសមរកគ្មាន
មានតែស្រូវស្រែទ្រព្យដែលមាន
បានជាទ្រាំរៀនទៅមិនបាន ។

៦- ចំណេះតិចតួចស្ទួចចំណេះ
ក្សាន្តបានដែរអេះ សុខក្សេមក្សាន្ត
សាន្តសុខជីវិតឥតសុខសាន្ត
ធ្វើអ្វីទៅបានការអ្វីធ្វើ ។

. . . . . .

១០- មានតែផ្លូវមួយផ្លូវមួយមាន
វង់ចាំជំហាន កុំវេរង់
ខ្វង់ក៏មិនមែន មិនមែនខ្វង់
ធ្វើគ្រូខ្ញុំចង់ត្រូវតែធ្វើ ។

. . . . .

១៧- មិត្តអើយមើលទៀននៅផ្ទះមិត្ត

Buddhist Institute



ឆាប់ឆេះមិត្តអុជទៀនចេះឆាប់
ស្រាប់វិនាសរូបមិត្តឃើញស្រាប់
រាងរូបទៀនស្លាប់បាត់រូបរាង
១៨- ទៀនវិនាសពិតប៉ុន្តែទៀន
វាងវៃមែនមានគិតវៃវាង
ទៀងជាក់បំភ្លឺគេជាក់ទៀង
ភ្លឺគេបំព្រាងឱ្យគេភ្លឺ ។
១៩- ការធ្វើគ្រូគេគឺជាការ
ព្ញហើយគេថាយើងធ្លាប់ព្ញ
ឈឺចាប់មានរោគជូនកាលឈឺ
ឱ្យតែសិស្សភ្លឺដោយគ្រូឱ្យ ។
២០- ទៀនដូចជាគ្រូគ្រូដូចជាទៀន
ខ្សោយរូបសុខភាពតែងអន់ខ្សោយ
ក្រោយទៅរីងខ្លួនជាខាងក្រោយ
ភ្លឺចុះខ្ញុំឱ្យសិស្សបានភ្លឺ ។

មេសា ៥៨

Buddhist Institute

សូមរង់ចាំអានស្នាដៃទី ៣
ដែលសរសេររួច ហើយនៅចុងឆ្នាំ ១៩៦៩

Buddhist Institute